ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០១៦/២៦ គ.ជ.ប.ជ

# របាយការណ៍
# ស្ដីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែមករា និងទិសដៅខែកុម្ភៈ ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនារំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្សជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្ដាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្ដាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្ដែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្ដាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្ដាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្ដាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងខែមករានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៥.៨៥១លើក មានអ្នកចូលរួមសរុបចំនួន ៨១៩.៨៤១នាក់ ក្នុងនោះស្ត្រី ៤២៩.៥៦៩នាក់ (ប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០២៥ មានចំនួន ៨២៦.២៣៨នាក់) ថយចុះ ៦.៣៩៧នាក់ ស្មើនឹង ០,៧៧% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៥.៦១៣ | ៧៦៥.៧៤៤ | ៤០៣.៤៦៦ |
| ២ | កម្មវិធីផ្សេងៗ | ២៣៨ | ៥៤.០៩៧ | ២៦.១០៣ |
| សរុប | | ១៥.៨៥១លើក | ៨១៩.៨៤១នាក់ | ៤២៩.៥៦៩នាក់ |
| *(<u>សម្គាល់</u>៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នា តាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ១៥.៦១៣លើក មានអ្នកចូលរួមសរុបចំនួន ៧៦៥.៧៤៤នាក់ ក្នុងនោះស្ត្រីចំនួន ៤០៣.៤៦៦នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| តារាងទិន្នន័យវេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ/ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១៣១ | ២៦.០៧២ | ១៣.៦៩៧ | ៦០ | ៣.៤២១ | ១.៦៥២ |
| ២ | ខេត្តកណ្តាល | ៩៧ | ៦.១៣៧ | ២.៧៥៩ | ៩៩ | ៣.៧៦៣ | ១.៨២៤ |
| ៣ | ខេត្តបាត់ដំបង | ៧៣៥ | ៤១.១៤៦ | ២២.២៤៥ | ៥៧០ | ១៨.៣៥៣ | ១០.១៥៣ |
| ៤ | ខេត្តពោធិ៍សាត់ | ៦១៣ | ៤៦.៣២៧ | ២១.០០១ | ៣៥១ | ១៥.៨៦៩ | ៧.៨០៨ |
| ៥ | ខេត្តសៀមរាប | ៨៤៥ | ៧០.៣២១ | ៤៣.៨៩៧ | ៧៤១ | ២៧.៣០៦ | ១៧.៥២៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧៦៦ | ៤៣.៤៧៦ | ១៧.៤៦២ | ៤៧០ | ១៦.៤៦៥ | ៨.៥៦៩ |
| ៧ | ខេត្តកំពង់ចាម | ១.៧៣៧ | ៩៨.៧៣៩ | ៥១.៩៤៨ | ៩៥៩ | ៤៣.១៣៣ | ២៤.៣៤៦ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១៦ | ១.១៦៩ | ៧០៦ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | ខេត្តស្វាយរៀង | ៤៤៦ | ២៤.១២៣ | ១៣.៣៦៩ | ៤៣៤ | ១៥.៥៣៨ | ៨.២៤៨ |
| ១១ | ខេត្តប៉ៃលិន | | | | ៣៥ | ៦៥២ | ៣៧៤ |
| ១២ | ខេត្តកោះកុង | | | | ១.៧៧៥ | ៣៣.១៤៧ | ១៥.៦១១ |
| ១៣ | ខេត្តកំពត | ១៧ | ១៩២ | ៨៨ | ៩៨៩ | ៤៩.៣៤៧ | ២៦.៨៧៩ |
| ១៤ | ខេត្តកំពង់ធំ | ៥៥៥ | ៤៤.៨៧៤ | ២០.១០១ | ២៦៥ | ៩.៩៨៥ | ៥.៧៥៩ |
| ១៥ | ខេត្តតាកែវ | ៣២៧ | ១៣.១៨៥ | ៦.៦២៣ | | | |
| ១៦ | ខេត្តក្រចេះ | ៥០ | ៩០៥ | ៥២៣ | | | |
| ១៧ | ខេត្តកែប | ៥៥ | ៩.២៤២ | ៣.៩៩៦ | ១០៤ | ៤.៥៨៨ | ២.៨៦៩ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៥៩០ | ២៧.៣៨៤ | ១៦.៩៥៧ | ១៣៩ | ៤.៩២៤ | ២.៨៨៧ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៩៥៨ | ៦១.៨១២ | ៣២.២៥៧ | ៦៣០ | ២១.៨១៤ | ១១.៧៨២ |
| ២២ | ខេត្តត្បូងឃ្មុំ | ២ | ៧៧១ | ១៤៤ | ១០២ | ២.៩៥៩ | ១.២៣៣ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៤៩៩ | ១០.៦៦៩ | ៦.៣៧៣ | ១៩០ | ៤.៤៨០ | ២.៩៨៧ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៣ | ១.១១១ | ៦០៧ | ០១ | ៥៧ | ២៧ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៦២ | ៤.៤៣២ | ២.០៥៧ | ២៤ | ៩៨៩ | ៤៦៥ |
| សរុប | | ៨.៦៣៤ | ៥៣២.០៨៧ | ២៧៦.៨១០ | ៦.៩៧៩ | ២៣៣.៦៥៧ | ១២៦.៦៥៦ |
| សរុបរួម | | ១៥.៦១៣លើក | | ៧៦៥.៧៤៤នាក់ | | ៤០៣.៤៦៦នាក់ | |

❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | រាជធានី ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ០២ | ៨០០ | ៥០០ |
| ២ | ខេត្តកណ្ដាល | ០៨ | ៩.៧០៥ | ៣.៨៥៣ |
| ៣ | ខេត្តប៉ៃលិន | ០១ | ៥៨ | ១៧ |
| ៤ | ខេត្តសៀមរាប | ៣៨ | ៦.១០១ | ៣.០២៩ |
| ៥ | ខេត្តកំពង់ឆ្នាំង | ០២ | ៧៧ | ៤២ |
| ៦ | ខេត្តព្រះសីហនុ | ០១ | ២១៧ | ១៣០ |
| ៧ | ខេត្តស្វាយរៀង | ០១ | ០៧ | ០៥ |
| ៨ | ខេត្តក្រចេះ | ១៣ | ១.០៥៧ | ៦៧៨ |
| ៩ | ខេត្តបន្ទាយមានជ័យ | ៣ | ១.៤០២ | ២០១ |
| ១០ | ខេត្តកំពង់ស្ពឺ | ៦៧ | ៦.៦៨៥ | ៣.១៤២ |
| ១១ | ខេត្តតាកែវ | ៩៥ | ២៧.២៣៩ | ១៤.៣៩២ |
| ១២ | អង្គការ Friend International (សៀមរាប) | ០១ | ១៧៥ | ១០០ |
| ១៣ | អង្គការម៉ប់តាប៉ាង(ព្រះសីហនុ) | ០៣ | ៣៩៨ | ១៤ |
| ១៤ | អង្គការជនជាជីវិត(ព្រះសីហនុ) | ០៣ | ១៧៦ | |
| សរុប | | ២៣៨លើក | ៥៤.០៩៧នាក់ | ២៦.១០៣នាក់ |

**គ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់**

❖ ការផលិត និងចែកផ្សាយ សម្ភារផ្ដល់ព័ត៌មាននិងអប់រំ IEC (Information Education Communication Materials)

▪ រាជធានីភ្នំពេញ៖ រដ្ឋបាលក្រុងបានផ្សព្វផ្សាតាមរយៈ DVD Video ផ្ដល់ការអប់រំស្ដីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អ្នកទេសចរសរុបចំនួន ១.០១១.០០០នាក់ ទេសចរជាតិ ៩៨៧.០០០នាក់ ទេសចរបរទេស ២៤.០០០នាក់ (តាមផ្លូវថ្មើជើងចតុមុខ)។

▪ ខេត្តសៀមរាបៈ

- ក្រុងសៀមរាប ចែកខិត្តប័ណ្ណផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព និងលេខទូរស័ព្ទអាជ្ញាធរមានសមត្ថកិច្ចជូនប្រជាពលរដ្ឋ បានចំនួន ៦៥៩សន្លឹក

- ស្រុកពួក ចែកខិត្តប័ណ្ណព័ត៌មាន ស្តីពីការធ្វើចំណាកស្រុក ការស្វែងរកជំនួយ និងផលប៉ះពាល់នៃការប្រើប្រាស់នូវសារធាតុញៀន បានចំនួន ១៣.៥៧៧សន្លឹក

- មជ្ឈមណ្ឌលការងារខេត្ត ផ្សព្វផ្សាយនិងចែកខិត្តប័ណ្ណ/កម្មវិធី អំពីព័ត៌មានទីផ្សាការងារ បានចំនួន ៤០០ខិត្តប័ណ្ណ/កម្មវិធី (៤០០នាក់ ស្រី២០០នាក់)

- អង្គការមូលនិធិអេ២១ ចែកសាប៊ូមានភ្ជាប់ប័ណ្ណរាយការណ៍ ករណីសង្ស័យថាជាអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋកៀសសឹក ក្នុងស្រុកអង្គរធំ និងស្រុកប្រាសាទបាគង ចំនួន ២០០នាក់/ខិត្តប័ណ្ណ ស្រី ១៣៩នាក់។

▪ **ខេត្តព្រះវិហារៈ** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេកមន្ទីរការងារ និងគ្រុបតេលេក្រាមមន្ទីរការងារ ជាមួយសហគ្រាស គ្រឹះស្ថានក្នុងខេត្ត និងចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន ១៦សន្លឹក អ្នកទទួលបាន ៤៩២នាក់ ស្រី ១៤១នាក់។

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង នៅតាមបណ្តាស្ថានីយវិទ្យុ ទូរទស្សន៍ តាមបណ្តាញសង្គម ការផលិតស្ប៉ត វីដេអូអប់រំខ្លីៗ ទទួលបានលទ្ធផលដូចខាងក្រោមៈ

▪ ខេត្តសៀមរាបៈ

- មន្ទីរព័ត៌មានខេត្ត បានផលិតកម្មវិធី២សំខាន់ៗ ធ្វើការផ្សាយផ្ទាល់តាមរយៈវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត ទូរទស្សន៍ខ្សែកាបអង្គរ(ប៉ុស្តិ៍លេខ៩៥) ប្រព័ន្ធអនឡាញ និងតាមប្រព័ន្ធបណ្តាញសង្គមហ្វេសបុក (Nokorphnom FM 103 និងទូរទស្សន៍ជាតិខេត្តសៀមរាប) ដើម្បីធ្វើការផ្សព្វផ្សាយអប់រំ ស្តីពីអំពើហិង្សានៅក្នុងគ្រួសារ ការធ្វើចំណាកស្រុកខុសច្បាប់ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់-ល-។ បានចំនួន ១៤២ លើក ក្នុងនោះផ្សាយផ្ទាល់ ៣៣លើក ចាក់ផ្សាយសារឡើងវិញ ១០៩លើក និងស្ប៉តអប់រំ ស្តីពីគ្រឿងញៀន និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ៥.១៦០ដង។

- មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត បានធ្វើការប្រជុំផ្សព្វផ្សាយ និងចេញសេចក្តីណែនាំចំពោះបណ្តាក្រុមហ៊ុនប្រតិបត្តិករអ៊ិនធឺណិត (ISP) ទាំងអស់ទូទាំងខេត្តសៀមរាប ស្តីពីការចូលរួមបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរត់ពន្ធមនុស្ស ការជួញដូរមនុស្សឆ្លងដែន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ ១លើក។

▪ **ខេត្តកំពង់ចាមៈ** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ក្នុងកម្មវិធីសន្ទនាមតិ ៤លើក ស្តីពីដំណើរការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស ការបង្ការទប់ស្កាត់ពលកម្មកុមារខុសច្បាប់ និងការធ្វើចំណាកស្រុកដោយស្របច្បាប់។

▪ **ខេត្តកំពង់ស្ពឺៈ** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិគិរីរម្យ អំពីស្ប៉តការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ រៀងរាល់ថ្ងៃក្នុងមួយថ្ងៃផ្សាយ ២០លើក សរុបចំនួន ៦០០លើក។

▪ **ខេត្តព្រៃវែងៈ** មន្ទីរព័ត៌មានខេត្ត តាមរយៈវិទ្យុបារាយណ៍អណ្តែក បានផ្សព្វផ្សាយសារអប់រំនៃការជួញដូរមនុស្ស បានចំនួន ៥០ដង ដោយក្នុង១ថ្ងៃ ៥លើក។

▪ **ខេត្តកោះកុងៈ** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយស្ប៉តអប់រំ ស្តីពីការជួញដូរមនុស្សជាអំពើខុសច្បាប់ បានចំនួន ១៨០លើក។

▪ ខេត្តបន្ទាយមានជ័យ៖ មន្ទីរព័ត៌មានខេត្ត តាមរយៈវិទ្យុសំលេងជនពិការភ្នែក បានផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន ៨លើក។

▪ ខេត្តតាកែវ៖ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ច្បាប់ស្តីពីការបង្ក្រាបអំពើរជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ៩ជំពូក ៥២មាត្រា បានចំនួន ២០ដង។

▪ ខេត្តប៉ៃលិន៖ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងមួយថ្ងៃ ៨លើក ស្មើនឹង ៤៩៦លើក ក្នុងមួយខែ។

▪ ខេត្តត្បូងឃ្មុំ៖ មន្ទីរព័ត៌មានខេត្ត តាមរយៈវិទ្យុជាតិ បានចាក់ស្ប៉ុតខ្លី ស្តីពីបុរសល្អ ស្ប៉ុតខ្លីអប់រំស្តីពីអំពើហិង្សាក្នុងគ្រួសារ ស្ប៉ុតការជួញដូរក្រៅប្រទេស បានចំនួន ១៣០ដង និងខ្លឹមសាររឿងពាក់ព័ន្ធការជួញដូរផ្លូវភេទចំនួន ៣២ដង ព្រមទាំធ្វើការផ្សព្វផ្សាយព័ត៌មាន ស្តីពីស្ត្រី និងកុមារ តាមវិទ្យុ និងទូរទស្សន៍ជាតិខេត្តបាន ៧អត្ថបទ។

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ ខេត្តសៀមរាប សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ តាមមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុកនិងអង្គការដៃគូ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីយើងធ្វើបាន របស់វិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត បានចំនួន ១១លើក៖

-ស្រុកប្រាសាទបាគង ជាវាគ្មិន ស្តីពីការការពារស្ត្រី និងកុមារដែលជាជនភៀសសឹកក្នុងមូលដ្ឋាន១លើក

-នាយកាិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត និងអង្គការមូលនិធិអេ២១ ជាវាគ្មិន ស្តីពីការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងសម័យបច្ចេកវិទ្យា ១លើក

-មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាវាគ្មិន ស្តីពីការយកចិត្តទុកដាក់ដល់ការសិក្សាចំពោះសិស្សានុសិស្សភៀសសឹក ១លើក

-ស្រុកក្រឡាញ់ និងស្រុកវ៉ារិន ជាវាគ្មិន ស្តីពីស្មារតីខ្មែរតែមួយ ខ្មែរស្រលាញ់ខ្មែរ ខ្មែរជួយខ្មែរ និងយើងរួមគ្នាដើម្បីជាតិ ៣លើក

-ស្រុកប្រាសាទបាគង ស្រុកជីក្រែង និងស្រុកសូទ្រនិគម ជាវាគ្មិន ស្តីពីការការពារសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋ ៣លើក

-វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ ជាវាគ្មិន ស្តីពីការទទួលបាន ឱកាសអាហារូបករណ៍១០០%ក្នុងការសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ១លើក

-មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្ត ជាវាគ្មិន ស្តីពីការជំរុញការដាំដំណាំបន្លែ នៅតាមមណ្ឌលភៀសសឹក ១លើក។

## ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

❖ ការផ្សព្វផ្សាយ

▪ ខេត្តតាកែវ៖ បានផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់តាមរោងចក្រ សហគ្រាស និងសិប្បកម្ម ចំនួន១៤មូលដ្ឋាន មានកម្មករចំនួន ១៩៩.៥០០នាក់ ស្រី ៩៦.៩៥០នាក់។

❖ ការធ្វើអធិការកិច្ចការងារ

▪ ខេត្តកណ្តាល៖ មន្ទីរការងារ បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះធ្វើអធិការកិច្ចការងារពិសេសចំនួន ៧លើក ស្មើនឹង ៧សហគ្រាស គ្រឹះស្ថាន ចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស និងលក្ខខណ្ឌការងារ។ ក្នុងនោះមានសហគ្រាស គ្រឹះស្ថាន ៣ ត្រូវបានក្រុមកាងារធ្វើការដាក់កំហិត និងសហគ្រាស គ្រឹះស្ថាន ២ ត្រូវបានក្រុមកាងាររៀបចំឯកសារត្រៀមផាកពិន័យ។

▪ ខេត្តសៀមរាប៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងកម្មករខ្មែរ និងបរទេស និងការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ

-ធ្វើបច្ចុប្បន្នភាព សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីបញ្ចូលក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសរុបចំនួន ៣.៣៧២សហគ្រាស មានកម្មករនិយោជិត ចំនួន ៣៨.៥១៦នាក់ ស្រី ១៨.០៩០នាក់

-បានផ្តល់សៀវភៅការងារទិដ្ឋាការចេញ-ចូល លើសៀវភៅការងារដល់កម្មករ និយោជិតខ្មែរ សរុប ២៨៩នាក់ ស្រី ១០៦នាក់

-បានបានផ្តល់ប័ណ្ណការងារជនបរទេស ចំនួន ១១២នាក់ ស្រី ៣៤នាក់ (ផ្តល់ប័ណ្ណការងារថ្មី និងទិដ្ឋាការចូល ៥នាក់ ស្រី ២នាក់ និងពន្យាសុពលភាពលើប័ណ្ណការងារ ១០៧នាក់ ស្រី ៣២៨នាក់)

-បានពិនិត្យ លើការស្នើសុំកូតាប្រើប្រាស់ហត្ថពលកម្មបរទេស ចំនួន ៣៩ក្រុមហ៊ុន

-បានដោះស្រាយវិវាទការងារបុគ្គល ១សហគ្រាស មានវិវាទ ១ករណី (សះជា ១ករណី) មូលហេតុនៃវិវាទពាក់ព័ន្ធនឹងបញ្ឈប់ការងារ ១ករណី។

**ក.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរតាមផ្លូវច្បាប់ បានចំនួន ២៥៨នាក់ ស្រី ១២នាក់ មាន២២សញ្ជាតិ រួមមានចិន ១៥២នាក់ស្រី១, កូរ៉េខាងត្បូង ៤២នាក់ស្រី៤, អាម៉េរិក ២២នាក់ស្រី២, បារាំង៩នាក់, កាណាដា៧នាក់, អូស្ត្រាលី៤នាក់ស្រី២, អាល្លឺម៉ង់៣នាក់, វៀតណាម២នាក់, នូវែលសេឡង់២នាក់ស្រី១, អង់គ្លេស២នាក់, ជប៉ុន២នាក់, ឥណ្ឌា១នាក់, ឥណ្ឌូនេស៊ី១នាក់, អ៊ីតាលី១នាក់, ស៊ុយអែត១នាក់, មីយ៉ាន់ម៉ា១នាក់(ស្រី) អាហ្វ្រិកខាងត្បូង១នាក់(ស្រី), ម៉ាឡេស៊ី១នាក់, ហ្វីលីពីន ១នាក់, ស្លូវ៉ាគី១នាក់, ន័រវេស១នាក់, ស្រីលង្កា១នាក់។ *និងបានវាយតម្លៃបញ្ជូនឯកសារទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន ៤០៧នាក់ ស្រី ១៦នាក់។*

❖ ការផ្សព្វផ្សាយ

▪ ខេត្តកំពង់ចាម៖ បានផ្សព្វផ្សាយច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបែបបទនិងនីតិវិធី នៃការរៀបអាពាហ៍ពិពាហ៍រវៀងពលរដ្ឋខ្មែរ និងជនបរទេស ចំនួន ៤៧២លើក អ្នកចូលរួម ១៦.២១៧នាក់ ស្រី៨.៤១៣នាក់។

**ក.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស**

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង រាជធានី ខេត្ត សរុបចំនួន ៣៨.៦៦៧នាក់ ស្រី ១៦.៩២៩នាក់ អនីតិជន ២១៩នាក់ ស្រី ៩៨នាក់ ក្នុងនោះ ៖

- ស្របច្បាប់ចំនួន ៣៣.១៤២នាក់ ស្រី ១៤.៦២៦នាក់ អនីតិជន ៧៨នាក់ ស្រី ៣៥នាក់
- មិនស្របច្បាប់ចំនួន ៥.៣៧៦នាក់ ស្រី ២.២៥៦នាក់ អនីតិជន ១៣៩នាក់ ស្រី ៦១នាក់
- ដាច់ការទាក់ទងចំនួន ១៤៩នាក់ ស្រី ៤៧នាក់ អនីតិជន ០២នាក់ ស្រី)។

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ១៧.៣០៥នាក់ ស្រី ៨.០០០នាក់ អនីតិជន ៣០៩នាក់ ស្រី ១១៧នាក់។

▪ **លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖** បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងបានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករចំណាកស្រុក ទៅក្រៅប្រទេស | | | | ចំនួនពលករវិលត្រឡប់ ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្ដាល | ៧.១៤០ | ៣.៨៨១ | ៩៣ | | | | | |
| ២ | កំពង់ចាម | ១២.៨២១ | ៥.៨៩១ | | | | | | |
| ៣ | កំពង់ឆ្នាំង | ២៤ | ០៩ | | | ៣០ | ១២ | | |
| ៤ | កំពង់ស្ពឺ | ៩៣៨ | ១៧០ | | | ២៦ | ១៣ | | |
| ៥ | កំពត | | | | | ៦.៣៥០ | ២.៩៣៨ | | |
| ៦ | កែប | | | | | | | | |
| ៧ | កោះកុង | ១.២២០ | ៦០៧ | ៩០ | ៣៥ | | | | |
| ៨ | ក្រចេះ | ១.៨៥១ | ៨៣៣ | | | ២.០៥៨ | ៨៨៩ | ៨៧ | ៣៥ |
| ៩ | តាកែវ | | | | | | | | |
| ១០ | ត្បូងឃ្មុំ | ១១.៧៣៩ | ៥.៤៧៥ | ៧២ | ៣៩ | | | | |
| ១១ | បាត់ដំបង | ២២១ | ១០៥ | | | ៧០៧ | ៣៤៨ | ២២១ | |
| ១២ | បន្ទាយមានជ័យ | | | | | | | | |
| ១៣ | ប៉ៃលិន | | | | | | | | |
| ១៤ | ឧត្តរមានជ័យ | ៩.១៧៦ | ៤.៦៨៩ | ០២ | | | | | |
| ១៥ | ពោធិ៍សាត់ | ៤៦៦ | ២៤៥ | ១៩ | ០៦ | ១៧៤ | ៦៦ | | |
| ១៦ | ព្រះវិហារ | ១.១៤២ | ៥០០ | | | ១.១៤២ | ៥០០ | | |
| ១៧ | ព្រះសីហនុ | ០៤ | | | | | | | |
| ១៨ | ព្រៃវែង | ៨៨ | ២៣ | | | ១.៤៧៩ | ៩៨៤ | ៣៦ | ១៦ |
| ១៩ | ភ្នំពេញ | | | | | | | | |
| ២០ | មណ្ឌលគិរី | ៨០ | ២៨ | ១៣ | ០៥ | | | | |
| ២១ | រតនៈគីរី | | | | | | | | |
| ២២ | សៀមរាប | ២២.៥៣០ | ១០.៤៩៧ | ១.១៩០ | ៥៣៤ | ៤៤០ | ២១១ | ៨២ | ៦៩ |
| ២៣ | ស្វាយរៀង | ៤.៩៥៤ | ២.៦៥៥ | | | ៤.៨៩៣ | ២.៧១៣ | | |
| ២៤ | ស្ទឹងត្រែង | | | | | | | | |
| ២៥ | ឧត្តរមានជ័យ | | | | | | | | |
| | **សរុបរួម** | **៧៤.៣៩៤** | **៣៥.៦០៨** | **១.៤៧៩** | **៦១៩** | **១៦.១៥៧** | **៨.១៧៤** | **៤២៦** | **១២០** |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

- <u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ)</u>

▪ ខេត្តកោះកុង៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន ៤លើក មនុស្សចំនួន ៣៥នាក់ ស្រី ៨នាក់ កុមារ ១នាក់(ស្រី)។

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់មកពីប្រទេសថៃនិរទេស ចំនួន ៦៦នាក់ (ប្រុស១៦នាក់ ស្រី២៨នាក់ កុមារ៨នាក់ កុមារី១៤នាក់)។

▪ មណ្ឌលទទួលពលករកំរៀង បានទទួលពលករខ្មែរបញ្ជូនត្រឡប់ពីអាជ្ញាធរថៃ ចំនួន ៣.៣១៧នាក់ ក្នុងនោះស្ត្រី ១.៣៤៩នាក់ (ស្ត្រីមានកូនតូចមកជាមួយ ២៧៩នាក់ និងស្ត្រីមានផ្ទៃពោះ ៣៩នាក់) អនីតិជន ១៨៨នាក់ (អនីតិជនស្រី ៨៨នាក់) និងជនមានពិការភាព ៥នាក់(ស្ត្រី ១នាក់)។

**ក.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ ការផ្សព្វផ្សាយ

▪ ខេត្តសៀមរាប

○ អង្គការមូលនិធិអេ២១ សហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយ អំពីកម្មវិធីបង្ការទប់ស្កាត់អំពើកេងប្រវ័ញ្ចលើកុមារ នៅមណ្ឌលកៀសសឹកវត្តប្រាសាទលលៃ ស្រុកប្រាសាទបាគង ១លើក មានអ្នកចូលរួមចំនួន ៥០នាក់ ស្រី ៣០នាក់។

○ អង្គការ Friend International (កល្យាណមិត្ត) បានធ្វើការអប់រំផ្សព្វផ្សាយ ស្តីពីសិទ្ធិកុមារ និងកិច្ចការពារកុមារ ដល់ក្រុមគោលដៅរងគ្រោះ និងងាយរងគ្រោះ ដោយបានធ្វើការបណ្តុះបណ្តាលជាក្រុមតូចៗ ឬលក្ខណៈបុគ្គល ដល់កុមារ និងអាណាព្យាបាល នៅតាមសហគមន៍ និងជំរុំកៀសសឹក ចំនួន ១៤៩លើក ដែលមានអ្នកចូលរួមសរុប ៤.១៣៩នាក់ ស្រី ២.០២៧នាក់ ក្នុងនោះមានកុមារចំនួន ២.០២៨នាក់ កុមារី ៩៩៣នាក់។

**ក.៥. ការលើកកម្ពស់ជីវភាព**

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ខេត្តសៀរាប

○ មជ្ឈមណ្ឌលការងារខេត្ត បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន ១៤៦កន្លែង។ បានរៀបចំពិព័រណ៍ការងារចល័ត ១លើក អ្នកចូលរួមចំនួន ២៣០នាក់ ស្រី ១៥០នាក់។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ បានចំនួន ៣២នាក់ ស្រី ១៧នាក់ (ពលករ ១២នាក់ ស្រី ៧នាក់)។ បានផ្គូផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ១៤៤នាក់ ស្រី ៨៥នាក់ (ពលករ ៦៦នាក់ ស្រី៤០នាក់)។ អ្នកទទួលបានការងារធ្វើសរុប ២៤នាក់ ស្រី ១២នាក់ (ពលករ ៩នាក់ ស្រី ៤នាក់)។ ផ្តល់ការប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើ បានចំនួន ១២៥នាក់ ស្រី ៧៥នាក់។

○ មន្ទីរឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត បានជំរុញ និងលើកទឹកចិត្តដល់សហគ្រិន ដោយបានណែនាំពីចំណុចដែលត្រូវកែលម្អ និងចំណុចត្រូវធ្វើបន្ថែមទៀត ដើម្បីផលិតកម្មមានដំណើរការ បានជួយកម្មករឱ្យមានការងារធ្វើនៅនឹងកន្លែង បានចំនួន ២៤មូលដ្ឋាន ដែលមានម្ចាស់អាជីកម្ម កម្មករនិយោជិតសរុប ១៨០នាក់ ស្ត្រី ១០៥នាក់។

○ មន្ទីរពាណិជ្ជកម្មខេត្ត បានចុះតាមដានវឌ្ឍនភាព និងពិភាក្សាជាមួយគណៈកម្មការចង្កោមអាជីវកម្ម ស្តីពីការប្រើប្រាស់ SDF និងផ្ទះសំណាញ់ នៅឃុំកៀនសង្កែ ឃុំដានរុន ស្រុកសូទ្រនិគម និងឃុំកន្ទ្រាំង ស្រុកប្រាសាទបាគង ២លើក មានអ្នកចូលរួមចំនួន ១២នាក់ ស្រី ៨នាក់។

○ អង្គការ Friend International (កល្យាណមិត្ត) បានស្វែងរកការងារ និងគាំទ្រអតិថិជនឱ្យមានការងារ និងមុខរបរ ចំនួន ៥៦នាក់ ស្រី ៣៩នាក់ ដោយក្នុងនោះ មានអតិថិជនបានដាក់ឱ្យមានការងារធ្វើ ៣១នាក់ ស្រី ២១នាក់ និងអតិថិជន ២៥នាក់ ស្រី ១៨នាក់ បានដាក់ជាមុខរបរអាជីវកម្មខ្នាតតូច។

▪ **ខេត្តកំពង់ចាម៖** មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្ត បានបើកវគ្គបណ្តុះបណ្តាល (កាត់ដេរ ត្បាញសំអាងកាយ) ដើម្បីបង្កើនជាមុខរបរចិញ្ចឹមជីវិត ចូលរួមកាត់បន្ថយភាពក្រីក្រនៅសហគមន៍ បាន ១វគ្គ អ្នកចូលរួមចំនួន ១១០នាក់(ស្រី)។

▪ ខេត្តស្វាយរៀង៖ មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន២ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារសុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋមចំនួន ២វគ្គ អ្នកចូលរួមចំនួន ៤១នាក់ ស្រី១៧នាក់។

▪ ខេត្តប៉ៃលិន

○ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋានតាមភូមិ ឃុំ សង្កាត់ ផ្សព្វផ្សាយ និងជួយស្វែងរកការងារជូនបងប្អូនពលករខ្មែរវិលត្រឡប់ពីប្រទេសថៃចំនួន ៣៥នាក់ ស្រី ១២នាក់

○ បានចុះស្រង់ស្ថិតិតាមសហគ្រាស គ្រឹះស្ថាន ពីតម្រូវការជ្រើសរើសកម្មករនិយោជិតក្នុងខេត្ត និងបានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងពលករដែលត្រឡប់មកពីប្រទេសថៃតាមរយៈហ្វេសប៊ុកផេក របស់មន្ទីរស្តីពីការចែកខិត្តប័ណ្ណ ការចងបដានៅតាមទីកន្លែងរដ្ឋបាលសាធារណៈ និងសហការជាមួយអាជ្ញាធរមូលដ្ឋានទាំង ៨ ឃុំ សង្កាត់ ដែលមានសហគ្រាស គ្រឹះស្ថាន ២០ កំពុងមានតម្រូវការកម្មករនិយោជិតសរុប ៥៤នាក់ ស្រី ១៥នាក់។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ក្រុមការងារការអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ១៤ករណី (ប្រៀបធៀបនឹងខែធ្នូ ឆ្នាំ២០២៥ មានចំនួន ២៧ករណី គឺមានការថយចុះ១៣ករណី) ស្មើនឹង៤៨,១៤%

○ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ១៨នាក់ ស្រី ០២នាក់ ជនបរទេស ០៤នាក់ (ជនជាតិចិន)។

○ សង្គ្រោះជនរងគ្រោះចំនួន ៩៧នាក់ ស្រី ៣៦នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ០៨នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ១៥នាក់ ស្រី១១នាក់ អាយុ១៨ឆ្នាំឡើង ៧៤នាក់ ស្រី១៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៨៣នាក់ និងទៅគ្រួសារ ១៤នាក់)។

ក្នុងនោះបែកជា៖

✚ <u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ០៣/១២ករណី (ថយចុះ ០៩ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៦៥នាក់ ស្រី០៤នាក់ មានអាយុ១៥-១៧ឆ្នាំ ០៦នាក់ ស្រី០២នាក់ អាយុ១៨ឆ្នាំឡើង ៥៩នាក់ ស្រី០២នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៥៩នាក់ ទៅគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | ០១ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០២ | ០៣ | ៦៤(០៤) |
| *សរុប* | *០៣ករណី* | *០៤នាក់* | *៦៥(០៤)នាក់* |

- <u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>

បង្ក្រាបបាន ១១/១៥ករណី (ថយចុះ ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៤នាក់ ស្រី០២នាក់ ជនជាតិចិន ០៤នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៣២នាក់(ស្រី) មានអាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុ១៨ឆ្នាំឡើង ១៥នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ២៤នាក់ គ្រួសារ ០៨នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| សញ្ចារកម្ម | ០១ | ០៤ | ចិន៤ | ០៣ |
| សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០២ | | ២១ |
| រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | | ០១ |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | | ០១ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | | ០៦ |
| *សរុប* | *១១ករណី* | *១៤នាក់* | *០៤នាក់* | *៣២(ស្រី)នាក់* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនចាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេសចំនួន ៧៥នាក់(ប្រុស១នាក់ ស្រី៣២នាក់ កុមារី៤២នាក់) ក្នុងនោះ៖

- ក្នុងប្រទេសចំនួន ៦៦នាក់ (ប្រុស១នាក់ ស្រី២៤នាក់ អនីតិជនស្រី៤១នាក់) បទល្មើសសញ្ចារកម្ម
  - ខ្មែរ ៦២នាក់ (អនីតិជនស្រី៤១នាក់) មានអគ្គស្នងការដ្ឋាននគរបាលជាតិ ៥៣នាក់ (អនីតិជនស្រី ៣៥នាក់) និងកងរាជអាវុធហត្ថរាជធានីភ្នំពេញ ៩នាក់ (អនីតិជនស្រី៦នាក់)
  - បរទេស ០៤នាក់(ប្រុស១នាក់ ស្រី៣នាក់) មានជនជាតិឡាវ ៣នាក់ស្រី(សញ្ចារកម្ម) និងមីយ៉ាន់ម៉ា ១នាក់ប្រុស(កម្លាំងពលកម្ម)។
- ប្រទេសចិនចំនួន ៩នាក់ (ស្រី៨នាក់ កុមារី១នាក់)ករណីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ។

➢ *បានធ្វើការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញសរុបចំនួន ៧៥នាក់ (ប្រុស ១នាក់ ស្រី៣២នាក់ កុមារី៤២នាក់)។*

### គ.២. ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការចំនួន ៧៥នាក់(ប្រុស១នាក់ ស្រី៣២នាក់ កុមារី៤២នាក់) ក្នុងនោះ៖ អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ៤នាក់ស្រី អង្គការការីតាសកម្ពុជា ៩នាក់(ប្រុស១នាក់ ស្រី៧នាក់ កុមារី១នាក់) មន្ទីររាជធានី ខេត្ត ៦២នាក់(ស្រី ២១នាក់ កុមារី៤១នាក។

### គ.៣. ការតាមដានជនរងគ្រោះ

បានតាមដានជនរងគ្រោះ ចំនួន ១២៧នាក់(ប្រុស៨នាក់ ស្រី១១៩នាក់)។

### គ.៤. ការបិទករណីជនរងគ្រោះ

បានបិទករណី ជនរងគ្រោះ ចំនួន ២២នាក់(ស្រី២១នាក់ កុមារី១នាក់)។

### ឃ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

#### ឃ.១. កិច្ចសហប្រតិបត្តិការ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចូលរួមពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ក្នុងគោលបំណងដើម្បីកំណត់កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នារវាង ក្រសួងមហាផ្ទៃ និងអង្គការ IJM ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្ស រួមមាន អំពើកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងវិស័យការងារនេសាទ ស្ត្រីបម្រើតាមផ្ទះ សុំទាន កម្មករសំណង់ រោងចក្រ កសិកម្ម និងឧស្សាហកម្ម ព្រមទាំងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ ទីស្តីការក្រសួងមហាផ្ទៃ។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប បានសហការ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ UNICEF រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់យុត្តិធម៌អនីតិជន និងតួនាទីភារកិច្ចរបស់ភ្នាក់ងារសង្គមកិច្ច ដល់ភ្នាក់សង្គមកិច្ចនៃរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តសៀមរាប។ | ០១ | ១១៦ | ៥៦ |
| ២ | ខេត្តកណ្តាល៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយរដ្ឋបាលស្រុកលើកដែក និងអង្គការអេផល រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើប្រព័ន្ធអនឡាញ នៅសាលាស្រុកលើកដែក។ | ០១ | ៣៧ | ១៣ |
| | *សរុប* | *០២វគ្គ* | *១៥៣នាក់* | *៦៩នាក់* |

#### ក.២. សិក្ខាសាលា

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីសម្បទា បានសហការជាមួយគម្រោង JICA និងអង្គការអាស៊ានអេច (ASEAN-ACT) រៀបចំសិក្ខាសាលាផ្សព្វផ្សាយដាក់អនុវត្តសាកល្បង ស្តីពី«គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដែលបានកែសម្រួលរួចគម្រោងការអភិវឌ្ឍសមត្ថភាព ដើម្បីជួយដល់ជនរងគ្រោះ ដែលរួចពីការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ៣វគ្គ មានសិក្ខាកាមចូលរួមចំនួន **១៦៤**នាក់ ស្រី **៦៧**នាក់ ក្នុងនោះ៖

- គម្រោងJICA នៅខេត្តត្បូងឃ្មុំ **១**វគ្គ អ្នកចូលរួម **៥៣**នាក់ ស្រី **១៩**នាក់។ និងខេត្តសៀមរាប **១**វគ្គ អ្នកចូលរួម **៥៩**នាក់ ស្រី **២៨**នាក់។

- អង្គការអាស៊ានអេច(ASEAN-ACT) ខេត្តស្វាយរៀង **១**វគ្គ អ្នកចូលរួម **៥២**នាក់ ស្រី**២០**នាក់។

▪ ខេត្តសៀមរាប បានសហការជាមួយនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំកិច្ចសិក្ខាសាលាតម្រង់ទិសលើសៀវភៅណែនាំ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តសៀមរាប ១វគ្គ មានសិក្ខាកាមចូលរួមចំនួន ៧៨នាក់ ស្រី ៣៧នាក់ នៅសាលាខេត្តសៀមរាប។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានរៀបចំកិច្ចប្រជុំចំនួន ៨លើក មានអ្នកចូលរួមចំនួន **១៧៤**នាក់ ស្រី ២៦នាក់ ក្នុងនោះ៖

- កិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ តាមប្រព័ន្ធអនឡាញ(Zoom meeting) ជាមួយក្រុមការងារលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ទាំង២៥ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៦០នាក់។

- **កិច្ចប្រជុំអន្តរក្រសួងចំនួន ២លើក អ្នកចូលរួមចំនួន ៤៦នាក់ ស្រី ១០នាក់** -កិច្ចប្រជុំវិសាមញ្ញ ដើម្បីត្រៀមរៀបចំកម្មវិធី «**ទិវាអន្តរជាតិសុវត្ថិភាពអ៊ីនធឺណេត**» ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ ខាងមុខនេះ ដែលសមាសភាពចូលរួមមកពីក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ សរុបចំនួន **២៤**នាក់ ស្រី **៦**នាក់។ និងកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាង អនុស្សរណៈនៃការយោគយល់ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រេស៊ីល ក្នុងគោលបំណងដើម្បីកំណត់ការអនុវត្តកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលគ្នា រវាងរដ្ឋភាគីទាំងពីរ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្ស អ្នកចូលរួមចំនួន **២២**នាក់ ស្រី ៤នាក់ នៅបន្ទប់ប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។

- **កិច្ចប្រជុំផ្ទៃក្នុង ចំនួន ៥លើក អ្នកចូលរួមចំនួន ៦៨នាក់ ស្រី ១៦នាក់**

○ ពិនិត្យវឌ្ឍនភាពការអនុវត្តការងារ ឆ្នាំ២០២៥ លើកទិសដៅអនុវត្ត ឆ្នាំ២០២៦ និងពង្រឹងការអនុវត្តវិន័យក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន **២៧**នាក់ ស្រី **៦**នាក់

○ ពិនិត្យរបាយការណ៍ ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបរបាយការណ៍ GCM អ្នកចូលរួម **១៣**នាក់ ស្រី ៤នាក់

○ ពិនិត្យ និងការផ្តល់ធាតុចូលលើកម្រងសំណួរ នៃរបាយការណ៍ ស្តីពីការរកឃើញទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ឆ្នាំ២០២៥ របស់ក្រសួងការងារ សហរដ្ឋអាមេរិក ៣លើក អ្នកចូលរួម ២៨នាក់ ស្រី៦នាក់។

▪ **ខេត្តកណ្តាល**

- រដ្ឋបាលខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពប្រចាំឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តការងារបន្តឆ្នាំ២០២៦ ចំនួន១លើក ក្រោមអធិបតីភាព ឯកឧត្តម **អង មង្គល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងឯកឧត្តម **គួច ចំរើន** អភិបាល នៃគណៈអភិបាលខេត្ត ដែលមានវត្តមានចូលរួមចំនួន ៣៦៥នាក់ ស្រី ៥០នាក់។

- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង/ស្រុក និងឃុំ/សង្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែមករា ដើម្បីធ្វើការតាមដាន និងត្រួតពិនិត្យលើការអនុវត្តការងារ ៧លើក អ្នកចូលរួមចំនួន ១៥៣នាក់ ស្រី ៧៤នាក់។

▪ **ខេត្តកែប**

- បានរៀបចំសន្និបាទបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២៦ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **សោម ពិសិដ្ឋ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ១លើក អ្នកចូលរួមចំនួន ៣០៩នាក់។

- បានរៀបចំកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ផ្សព្វផ្សាយពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផលប៉ះពាល់នៃការធ្វើចំណាក់ស្រុកដោយខុសច្បាប់ **១លើក** ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **សោម ពិសិដ្ឋ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត មានអ្នកពាក់ព័ន្ធចូលរួមចំនួន ៥២នាក់។

- **ខេត្តព្រៃវែង**

- បានរៀបចំពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ ២០២៦ របស់រដ្ឋបាលខេត្តព្រៃវែង ក្រោមអធិបតីភាព ឯកឧត្តម **ស្បោង សារ៉ាត** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **សួន សុម៉ាលីន** អភិបាល នៃគណៈអភិបាលខេត្ត **១លើក** មានអ្នកចូលរួមចំនួន ៤៤៩នាក់។

- បានរៀបចំពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ ២០២៦ របស់រដ្ឋបាលខេត្តព្រៃវែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រៃវែង **១លើក** ដោយមានសមាសភាពចូលរួមសរុបចំនួន ៤៨១នាក់។

**ខ.២. ជំនួបពិភាក្សាការងារ**

- លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
  - បានដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលជួបជាមួយ តំណាងអង្គការ IJM ពិភាក្សាការងារដើម្បីបន្តពង្រឹងកិច្ចសហការក្នុងភាពជាដៃគូអភិវឌ្ឍ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រជាតិ
  - បានជួបពិភាក្សាការងារជាមួយតំណាងអង្គការ IOM ដើម្បីសហការសម្របសម្រួលដោះស្រាយករណី នៃការកើនឡើងសំណើ សុំជំនួយពីចំនួនទេសន្តរប្រវេសន៍បរទេស ដែលមិនអាចវិលត្រឡប់ទៅប្រទេសកំណើតវិញ។

- លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានជួបពិភាក្សាការងារ ជាមួយតំណាងក្រសួងអប់រំ យុវជន និងកីឡា និងតំណាងអង្គការ Aple ស្តីពីការត្រៀមរៀបចំយុទ្ធនាការ គាំទ្រទិវាសុវត្ថិភាពអ៊ិនធឺណិត ឆ្នាំ២០២៦។

- **ខេត្តសៀមរាប៖** ក្រុមការងារកិច្ចសហប្រតិបត្តិការ (មន្ទីរកិច្ចការនារីខេត្ត) បានទទួលជួបពិភាក្សាការងារស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី ជាពលករទេសន្តរប្រវេសន៍ ជាមួយអង្គការ UN Women បាន **១លើក** នៅមន្ទីរកិច្ចការនារីខេត្ត។

### គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ១៦លើក។ (**ឧបសម្ព័ន្ធ**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត

- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យធកល្វែង
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថាជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាពមិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូងដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែកុម្ភៈ ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម

១០. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

១១. រៀបចំប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងទិសដៅអនុវត្ត ឆ្នាំ២០២៦

១២. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់៕

ថ្ងៃ..អង្គារ ៩កើត..ខែ..មាឃ.... ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី..២៧.. ខែ..មករា....ឆ្នាំ២០២៦
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ គ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ
## ការដឹកនាំ សម្របសម្រួល

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំ តាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោក តាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams)
  - កិច្ចប្រជុំរាយការណ៍ ស្តីពីការរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធ នៃការប្រព្រឹត្តទៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - ជាអធិបតីក្នុងពិធីបិទ សិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានកែសម្រួលរួច រៀបចំដោយក្រសួងសង្គមកិច្ច នៅសណ្ឋាគារវែគោ ខេត្តស្វាយរៀង
  - ដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារអង្គការមូលនិធិហាការអន្តរជាតិ និងមូលនិធិអង្គការអេ២១ ចុះសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈប្រើប្រាស់ គ្រឿងឧបភោគបរិភោគរបស់ គ.ជ.ប.ជ និងកញ្ចប់ជំនួយសង្គ្រោះបន្ទាន់ ដែលទទួលបានពីអង្គការទាំងពីរខាងលើក ដើម្បីចុះចែកជូនជនភៀសសឹក នៅវត្តស្វាយដង្គំ ឃុំពួក និងវត្តសសរស្តម្ភ ឃុំសសរស្តម្ភ ស្រុកពួក ខេត្តសៀមរាប សរុបចំនួន **៣៦៥គ្រួសារ**
  - ជាអធិបតី ក្នុងពិធីគាំទ្រជំនួយសម្រាប់តម្រូវការ មូលដ្ឋានដល់គ្រួសារពលករងាយរងគ្រោះ បានវិលត្រឡប់មកពីប្រទេសថៃ រៀបចំដោយអង្គការការីតាស់ស្វីស សហការដោយមណ្ឌលទទួលពលករកំរៀង ចំនួនសរុប **២០៧គ្រួសារ** ដោយក្នុងមួយគ្រួសារទទួលបាន ប្រាក់២០ម៉ឺនរៀល ក្នុងនោះស្រុកកំរៀងមាន ៦១គ្រួសារមកពី៦ឃុំ ស្រុកភ្នំព្រឹកមាន ៧២គ្រួសារមកពី៥ឃុំ និងស្រុកសំពៅលូនមាន ៧៤គ្រួសារ មកពី៦ឃុំ
- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំ ស្តីពីកិច្ចសហការរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងUNODC ROSEAP ពិភាក្សាទៅលើកម្មវិធីជាអាទិភាពក្នុងពេលបច្ចុប្បន្ន ការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានទាក់ទងទៅនឹងនិន្នាការថ្មី ព្រមទាំងស្វែងយល់ពីឱកាសក្នុងការពង្រឹងកិច្ចសហការបន្ថែមទៀត នៅក្នុងវិស័យដែលមានផលប្រយោជន៍ និងពង្រឹងសមត្ថភាព ក៏ដូចជាការគាំទ្របច្ចេកទេស ក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
  - សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគី ស្តីពីការរៀបចំ និងផ្តល់សុពលភាពលើផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦-២០២៧ ក្នុងការអនុវត្តកម្មវិធីការងារសមរម្យប្រចាំកម្ពុជា (DWCP) ក្រោមអធិបតីភាព ឯកឧត្តម **ហេង សួ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (២១ច្បាប់) លិខិតចូល (២០ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៤៣ច្បាប់) លិខិតចូល (២០ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - បានប្រជុំត្រៀមរៀបចំកម្មវិធីយុទ្ធនាការ គាំទ្រទិវាសុវត្ថិភាពអ៊ីនធឺណិត ឆ្នាំ២០២៦ ជាមួយក្រសួង ស្ថាប័ន
  - បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ៕

- បានចូលរួមកិច្ចប្រជុំពិនិត្យ និងផ្តល់ធាតុចូលលើកម្រងសំណួរ នៃរបាយការណ៍ ស្តីពីការរកឃើញទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ឆ្នាំ២០២៥ របស់ក្រសួងការងារ សហរដ្ឋអាម៉េរិក ក្រោមអធិបតីភាព លោកជំទាវ **សួស រដ្ឋាវី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលប្រជុំ ទីស្តីការក្រសួងការងារ។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អតសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រៀបចំដោយក្រសួងសង្គមកិច្ច ២លើក (ខេត្តស្វាយរៀង ខេត្តសៀមរាប)
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល ដើម្បីកសាងប្រភេទសេវា និងចំណាត់ថ្នាក់ប្រភេទករណី ក្នុងប្រព័ន្ធគ្រប់គ្រងករណីរួម រៀបចំអគ្គនាយកដ្ឋានគោលបាយសង្គមកិច្ច (ស.អ.យ) នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ
  - បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
  - បានប្រជុំផ្ទៃក្នុងត្រួតពិនិត្យ និងបូកសរុបរបាយការណ៍ប្រចាំខែមករា របស់ក្រុមការងារអនុវត្តច្បាប់ ដែលទទួលបានអគ្គស្នងការ ជូនទៅលេខាដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យសេចក្តីព្រាង របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៦ របស់គណៈកម្មការសាខាសមាគមនារី ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ **ជួញ សុផៃ** អនុប្រធានអចិន្ត្រៃយ៍ និងជាប្រធានលេខាធិការដ្ឋាន នៅបន្ទប់ប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ**
  - បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់សាកល្បង នូវគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អតសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប រៀបចំដោយក្រសួងសង្គមកិច្ច នៅខេត្តស្វាយរៀង
  - បានប្រជុំពិនិត្យ និងកែសម្រួល សេចក្តីព្រាងផែនការសកម្មភាព ឆ្នាំ២០២៦ របស់ក្រុមជំនួយកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ ដឹកនាំដោយលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។